ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១៤១/១៧ គ.ជ.ប.ជ.

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមិថុនា និងទិសដៅខែកក្កដា ឆ្នាំ២០១៧

## I. ស្ថានភាពទូទៅ

នៅក្នុងខែមិថុនា ឆ្នាំ២០១៧នេះ ស្ថានភាពពលករទេសន្តប្រវេសន៍នៅតាមបណ្តាច្រកព្រំដែនកម្ពុជា-ថៃ មានការប្រែប្រួលជាខ្លាំង ដោយអាជ្ញាធរថៃបានចាប់ពលករខ្មែរខុសច្បាប់បញ្ជូនត្រឡប់មកកម្ពុជាវិញយ៉ាងច្រើន បន្ទាប់ពីអាជ្ញាធរថៃប្រកាសឲ្យប្រើព្រះរាជក្រឹត្យថ្មី ស្តីពីការគ្រប់គ្រងពលករបរទេសទាំង៨ចំណុច ទាក់ទិននឹងបញ្ហានេះ អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានបើកកិច្ចប្រជុំជាបន្ទាន់ដើម្បីស្វែងរកវិធានការដើម្បីជួយពលករ និងដោះស្រាយរាល់ភាពប្រឈមទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហានេះ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលជាសេនាធិការ មានសកម្មភាពមមាញឹកជាមួយនឹងការងារប្រមូលព័ត៌មាន ទិន្នន័យ និងរបាយការណ៍ពីគ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងរាជធានី-ខេត្ត បានខិតខំយកចិត្តទុកដាក់ ជំរុញ ពង្រឹងកិច្ចសហប្រតិបត្តិការសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលជាច្រើន ដែលជាមោទនភាពសម្រាប់ការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេស ។ គ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ដើម្បីសម្រេចបាននូវគោលដៅផែនការរបស់ខ្លួន។ ដូចនេះ ស្នើសុំឲ្យ ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពិនិត្យឡើងវិញនូវការផ្តល់របាយការណ៍របស់ខ្លួនមកអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ហើយរបាយការណ៍ក្រសួង និងខេត្តមួយចំនួនត្រូវផ្ញើមកឲ្យបានទាន់ពេលកំណត់ តែក្រសួង និងខេត្តមួយចំនួនមានការយឺតយ៉ាវ ហើយបើយោងតាមសេចក្តីសម្រេចលេខ០៩៤/១៤ ស.ស.រ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេចក្តីសម្រេចលេខ០០១/១៤ ស.ស.រ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ការបូកសរុបរបាយការណ៍ដែលប្រមូលបានពីក្រុងស្រុកខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ស្តីពីសកម្មភាព លទ្ធផល ភាពប្រឈម ជុំវិញការប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅ ដាក់ជូនអភិបាលរាជធានី-ខេត្តដែលជាប្រធាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ដើម្បីពិនិត្យ និងចុះហត្ថលេខារួចបញ្ជូនទៅអគ្គលេខាធិការដ្ឋានថ្នាក់ជាតិមិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ។

របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានគឺ ៖

- សម្រាប់បណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានអគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់)

ចំនួន០១ ដែលបានផ្តល់របាយការណ៍ ។ ដោយឡែកក្រសួង ស្ថាប័ន ចំនួន៥ ដែលជាយន្តការសម្របសម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីជានាឲ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតមិនទាន់បានផ្ញើរបាយការណ៍។

- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋានរាជធានី/ខេត្តចំនួន១៥ ដែលបានផ្តល់របាយការណ៍ដូចជា៖ រាជធានីភ្នំពេញ ព្រះសីហនុ កំពត តាកែវ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង កំពង់ចាម និងខេត្តស្វាយរៀង។ ដោយឡែកលេខាធិការដ្ឋានខេត្តចំនួន១០គឺ ខេត្តកោះកុង កែប ប៉ៃលិន កំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល ព្រៃវែង ត្បូងឃ្មុំ រតនគិរី និងខេត្តមណ្ឌលគិរី នៅមិនទាន់បានផ្ញើរបាយការណ៍។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែមិថុនា ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

#### ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

##### ក.១.១-កិច្ចការច្បាប់

**❖ លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពង់ពិភាក្សារួមមាន៖
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" **(ច្បាប់ជាតិ)**
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" រវាង ព្រះរាជាណាចក្រកម្ពុជា និង(សាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ រដ្ឋាភិបាល បារាំង និងរដ្ឋាភិបាលរុស្ស៊ី )។
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី "**បត្យាប័ន**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និង (រដ្ឋាភិបាលអង់គ្លេស រដ្ឋាភិបាលប៉េរូ សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលរុស្ស៊ី ) និង
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**" ។

##### ក.១.២-លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចេញ៖

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។

ក.១.៣-អនុស្សរណៈ

❖ អនុស្សរណៈកំពុងរៀបចំ

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**" ។
- **ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International ។

## ខ.ការបង្ការទប់ស្កាត់

### ខ.១- កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញាងាយរងគ្រោះ៖

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន០៤ គឺប៉ុស្តិ៍ ច្រកប៉ោយប៉ែត ច្រកដូង ច្រកព្រំ ច្រកអូរស្មាច់ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**២៧.៩៤២**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (**របាយការណ៍ក្រុមការងារនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍**) ។

### ខ.២. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ:

- ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ តាមប្រធានបទ "**ភូមិ-ឃុំមានសុវត្ថិភាព**" បានចំនួន**១.៨៨២** លើក មានអ្នកចូលរួមសរុបចំនួន**១៨៣.៤៨៩**នាក់ (ធៀបនឹងខែមុន មានចំនួនត្រឹមតែ**៣២៦.៧៤៩**នាក់) ថយចុះចំនួន**១៤៣.២៦០**នាក់ ស្មើនឹង**៤៣,៨៤%** ក្នុងនោះស្ត្រីមានចំនួន**១០០.៤០០**នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តមអគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមក្នុងកម្មវិធីការងារ និងជីវិត ជាវាគ្មិនវិទ្យុ VOD ផ្សាយផ្ទាល់ពិភាក្សា ប្រធានបទ "**ស្ត្រីបម្រើសេវាកម្សាន្តស្នើឲ្យមានច្បាប់ការពារ**" នៅស្ទូឌីយោវិទ្យុសារិកា FM106.5MHz ។
- **ខេត្តបាត់ដំបង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធីសន្ទនាមតិ របស់វិទ្យុជាតិចំការចេក(FM92.75MHz) ក្រោមប្រធានបទ " ការដោះស្រាយវិវាទការងាររវាងកម្មករ និយោជិក និងនិយោជក " ។
- **ខេត្តសៀមរាប** ក្រុមការងារលេខាធិការដ្ឋានគ.ខ.ប.ជ ខេត បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាម ប៉ុស្តិ៍វិទ្យុចំនួន០៤លើក ។
- **ខេត្តកំពត** ក្រុមការងារលេខាធិកាដ្ឋានគ.ខ.ប.ជ បានសកាជាមួយមន្ត្រីជំនាញក្រុង/ស្រុក ឃុំ/សង្កាត់ បានធ្វើការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុក តាមយៈការចាក់ផ្សាយឌីស "**ជើងមេឃនៅឯណា**" នៅតាមរោងកាហ្វេ និងទីសាធារណៈផ្សេងៗ និងសារព័ត៌មានបណ្តាញសង្គម ក៏បានផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែរ ។

### ខ.៤. ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៥.១.-<u>វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ</u>

កងកម្លាំងនគរបាល វរៈការពារព្រំដែនគោក និងនគរបាលប៉ុស្តិ៍ តាមបណ្តាច្រករបៀងនៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ

ដោយមិនស្របច្បាប់ ឬតាមរយៈមេខ្យល់ ។ ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យារួច ហើយ កម្លាំងជំនាញបានណែនាំឲ្យពួកគាត់វិលទៅរកលំនៅដ្ឋានវិញ មានដូចតារាងខាងក្រោម ៖

**តារាងសកម្មភាពបង្ការ និងទប់ស្កាត់**

| ល.រ | លេខាធិការដ្ឋាន គ.ខ.ប.ជ | សកម្មភាពទប់ស្កាត់ | ចំនួនលើក | ចំនួនរួម | ស្រី | អនីតិជន |
|---|---|---|---|---|---|---|
| ១ | ខេត្តបន្ទាយមានជ័យ | - កម្លាំងនគរបាលប៉ុស្តិ៍គោករមៀត ប៉ុស្តិ៍អូរ៣ជាន់ និង វរៈនគរបាលការពារព្រំដែនគោកលេខ (៩១១ និង៨០៧) បានទប់ស្កាត់ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ ។ | ០៤ | ៥២ | ២៣ | ០៥ |
| ២ | ខេត្តព្រះវិហារ | - វរៈនគរបាលការពារព្រំដែនគោក បានទប់ស្កាត់ពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ ។ | ០១ | ០៧ | | |
| សរុប | | | ០៥ | ៥៩ | ២៣ | ០៥ |

### ខ.៥.២. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

ក្នុងខែមិថុនា ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្រង់ស្ថិតិ ទិន្នន័យ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងស្ត្រី-បុរសក្នុង ហាងម៉ាស្សា ខារ៉ាអូខេ ក្នុងគោលដៅចំនួន៣១០ គោលដៅ មានមនុស្សចំនួន២.២៦០នាក់ (ស្រី ១.៧៨៧នាក់) កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត មាន៖ ខេត្តតាកែវ កែប កំពត ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង ព្រះវិហារ និងខេត្តកំពង់ស្ពឺ ។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរ មនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅ ទូទាំងរាជធានី/ខេត្ត ។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន៤០លើក ខេត្តអនុវត្តន៍មាន ខេត្តសៀមរាប ស្វាយរៀង ព្រៃវែង និងខេត្តកំពង់ស្ពឺ ។
- ខេត្តព្រះសីហនុ ស្នងការដ្ឋាននគរបាល និងអង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្តាញភ្នាក់ងារ ចំនួន១៤៣នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្តាញ សហគមន៍ បណ្តាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ ។

## ខ.៦. គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

### ខ.៦.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- *បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក*

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងខែមិថុនា ឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

*តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែមិថុនា*

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មិថុនា | ៣៣០.២៦៧ | ១៧០.៥៨៦ | ៨.៧៣៤ | ៣.២២៩ | ១៨៦.០៩០ | ៨៥.០៤៩ | ៥៩៧ | ២៤៧ | ១៤៤.១៧៧ | ៨៥.៥៣៧ | ៨.១៣៧ | ២.៩៨២ | កើន ៦.៦៣៩ |

### ខ.៦.២ ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** របាយការណ៍ខែមិថុនា ឆ្នាំ២០១៧ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិផ្លូវគោក និងផ្លូវអាកាស ចំនួន**១៥២**លើក មានមនុស្សចំនួនចំនួន**៤.៦៤៥**នាក់ (ស្រី**១.៧០៣**នាក់ និងកុមារ**៤៨៧**នាក់ កុមារី**១៦**នាក់) ដែលចែកដូចតទៅ ៖
  - តាមផ្លូវអាកាស ចំនួន**៣៥**លើក មានមនុស្សចំនួន**៨៨**នាក់ (ស្រី**៤៣**នាក់)
  - តាមផ្លូវគោក ៖
    - ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន**១១៧**លើក មានមនុស្សចំនួន**៤.២៦២**នាក់ (ស្រី **១.៥៤៤**នាក់ កុមារ**៤៥៤**នាក់) ។
    - និងប៉ុស្តិ៍ច្រកទ្វារព្រំដែនភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង មនុស្សចំនួន**២៩៥**នាក់ (ស្រី **១១៦**នាក់ កុមារ**៣៣**នាក់ កុមារី**១៦**នាក់) ។

*ស្ថានភាព ៖*

- ❖ ក្រុមអនុវត្តន៍ច្បាប់រាយការថា មានពលរដ្ឋខ្មែរចំនួន**៩១០**នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ ហើយថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។
- ❖ **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន**១០៩**ជើង/រថយន្ត មានមនុស្សចំនួន**៥៦.១០**នាក់ (ស្រី**១.៦៤៩**នាក់) ក្នុងនោះកុមារ**៤៩៦**នាក់ (កុមារី**១៩៤**នាក់) បើប្រៀបធៀបនឹងខែមុន ពលរដ្ឋខ្មែរមានចំនួនតែ**៦១.៨១**នាក់ (ថយចុះចំនួន**១.៥៧១**នាក់ ស្មើនឹង**២៥.៤១%**) ។ ក្រោយពីធ្វើការសម្ភាសន៍រួច បានឲ្យយើងដឹងថា៖
  - ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន**១៨.៤៨**នាក់ តាមច្រករបៀងមាន**២.៧៦២**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**២.០៨៨**នាក់ និងតាមគេនាំ មាន **២.៥២២**នាក់ ។
  - តាមការសម្ភាសន៍៖ កុមារ**៣២នាក់/៥២នាក់** ទៅតាមឪពុកម្តាយ និងកុមារ**២០**នាក់ ទៅតាមបងប្អូន ។

### ខ.៧- ការបង្ការទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានធ្វើការសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសចំនួន **១៣០**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបក្នុងអាពាហ៍ពិពាហ៍ ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១៣/០៥ករណី (បើប្រៀបធៀបនឹងខែមុន មានការកើនឡើង០៨ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង បានចំនួន២៥នាក់ ក្នុងនោះស្រី០៨នាក់ យើងបានសង្គ្រោះជនរងគ្រោះចំនួន៣៦នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ បាន០៨នាក់ អាយុពី១៥-១៧ឆ្នាំ បាន០៥នាក់ និងអាយុ១៨ឆ្នាំឡើងទៅបាន២៣នាក់ (ហើយបានប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន២៣នាក់ អង្គការចំនួន០៣នាក់ និងប្រគល់ឲ្យគ្រួសារវិញចំនួន១០នាក់)។

**១. ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០៣/០៣ករណី (ស្មើ០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៧នាក់(ស្រី០៤នាក់) ក្នុងនោះសង្គ្រោះជនរងគ្រោះបានចំនួន០២នាក់ អាយុ១៨ឆ្នាំឡើង០២នាក់ (ប្រគល់ឲ្យគ្រួសារ០២នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១ | ១ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ១ | ២ | |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១ | ៤ | |
| *សរុប* | *០៣ករណី* | *០៧នាក់* | |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន១០/០២ករណី (កើន០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន១៨នាក់ (ស្រី០៤នាក់) ក្នុងនោះជនបរទេសសញ្ជាតិហូឡង់០១នាក់ និងសង្គ្រោះជនរងគ្រោះចំនួន៣៤នាក់ អាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០៥នាក់ និងអាយុ១៨ឆ្នាំឡើង២១នាក់ (ដោយប្រគល់ឲ្យគ្រួសារទាំងអស់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ១ | ៧ | |
| -សញ្ញារកម្មមានអនីតិជន | ១ | ២ | |
| -ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ១ | ២ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ | ហូឡង់១ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | |
| *សរុប* | *១០ករណី* | *១៨នាក់* | *១នាក់* |

## គ.២ កិច្ចការយុត្តិធម៌

### លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរ

មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ត្រូវបានដាក់បញ្ចូលទិន្នន័យសរុបទៅក្នុងរបាយការណ៍ឆមាសទី១ រួចហើយ ។

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- យោងស្ថិតិ **អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តច្បាប់)** បានធ្វើសម្ភាសន៍ពលកររងគ្រោះចំនួន២៥នាក់ ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី១៦នាក់ ឥណ្ឌូនេស៊ី០១នាក់ ថៃ០៥នាក់ ឡាវ០២នាក់ និងប្រទេសវៀតណាម០៣នាក់ (តាមការសម្ភាសន៍មានទៅតាមមេខ្យល់។

**ឃ.២ ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិម្បទា បានសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន២២នាក់ (ស្រី០២នាក់) កុមារ០៩នាក់ (កុមារី០៦នាក់) ក្នុងនោះ៖

- **ខេត្តបន្ទាយមានជ័យ**៖មជ្ឈមណ្ឌលសំចតប៉ោយប៉ែតចំនួន១០នាក់ (ស្រី០១នាក់)កុមារ០៣នាក់ កុមារី០៦នាក់
  - -សម្រាប់កុមារចំនួន០៦នាក់ បានទទួលថវិកាពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ថៃ ក្នុងម្នាក់៣០០០បាត (បីពាន់បាត) ត្រូវបានប្រគល់ឲ្យអង្គការទទួលកុមាររងគ្រោះស្នាក់នៅ ដើម្បីផ្គត់ផ្គង់កុមារមុនពេលធ្វើ សមាហរណកម្មទៅឲ្យគ្រួសារវិញ ។
  - -និងជនរងគ្រោះចំនួន០៤នាក់(ស្រី០១នាក់ កុមារ០១នាក់ កុមារី០២នាក់) មជ្ឈមណ្ឌល សំចតប៉ោយប៉ែត បានប្រគល់ទៅអង្គការដំណក់ទឹក ដើម្បីទទួលសេវាស្នាក់នៅ និងអប់រំបណ្តុះបណ្តាលក្នុង និងក្រៅប្រព័ន្ធ នូវជំនាញវិជ្ជាជីវៈផ្សេងៗ ។
- **ខេត្តកំពត** ៖មានអង្គការចំនួន០៥ មានអង្គការ(ពន្លឺព្រះអាទិត្យ ទស្សនៈពិភពលោក មេត្រីភាពដើម្បីក្តីសង្ឃឹម អន្តជាតិអាស៊ី ជួយសង្គ្រោះវាសនាកល្យាណមិត្ត សួននៃក្តីសង្ឃឹម និងមណ្ឌល HCC កោះកុង ឡូជ័សវើល និងអង្គការហាហ្គារាជធានីភ្នំពេញ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១១នាក់។
- **ខេត្តបាត់ដំបង** ៖ មន្ទីរសង្គមកិច្ចខេត្ត បានសហការជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ បញ្ជូនក្មេងស្រីរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ ឲ្យស្នាក់នៅក្នុងមណ្ឌលរាជធានីភ្នំពេញ ដើម្បីទទួលសេវាថែទាំ និងអប់រំបណ្តុះបណ្តាលនូវជំនាញវិជ្ជាជីវៈផ្សេងៗ ។

**ឃ.៣.ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **សមាហរណកម្មជនរងគ្រោះ**

យោងរបាយការណ៍មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិម្បទារាជធានី/ខេត្ត បានសហការជាមួយអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពាន និងអាជីវកម្មផ្លូវភេទ ទៅតាមសហគមន៍វិញ ០៤ខេត្ត ចំនួនសរុប២២នាក់ (ស្រី១៨នាក់) កុមារ១៥នាក់ (កុមារី១០នាក់) មកពី៖

- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រចេះ**៖ បានទទួលនារីរងគ្រោះដោយ អំពើជួញដូរមនុស្ស មកពីប្រទេសម៉ាឡេស៊ីចំនួន០២នាក់ និងនារីនារីរងគ្រោះដោយការធ្វើចំណាកស្រុកខុសច្បាប់មកពីប្រទេសឡាវចំនួន០១នាក់ បានធ្វើការអប់រំ ណែនាំមុននឹងសមាហរណកម្មទៅសហគមន៍វិញ ។

- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តស្វាយរៀង** បានទទួលពលករឆ្លងដែនខុសច្បាប់ ទៅប្រទេសវៀតណាមចំនួន២១នាក់ (ស្រី១៣នាក់ កុមាចំនួន១៥នាក់ កុមារី១០នាក់) តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត និងច្រកព្រៃល្អិ៍ និងបានធ្វើការអប់រំ ណែនាំមុននឹងសមាហរណកម្មទៅលំនៅដ្ឋានវិញ ។
- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ** បានទទួលនារីរងគ្រោះដោយ អំជួញដូរកម្លាំងពលកម្មមកពីប្រទេសម៉ាឡេស៊ីចំនួន០១នាក់ និងបានធ្វើការអប់រំ ណែនាំ មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។
- **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តពោធិ៍សាត់ បានសហការជាមួយ**នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការវតនៈ បានទទួលនារីរងគ្រោះដោយអំជួញដូរកម្លាំងពលកម្មមកពីប្រទេសម៉ាឡេស៊ីចំនួន០១នាក់ និងបានធ្វើការអប់រំ ណែនាំ មុននឹងសមាហរណកម្មទៅមាតា បីតាវិញ ។

## III. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១- ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន០៥វគ្គ មានសិក្ខាកាមចូលរួមចំនួន២៧០នាក់ ក្នុងនោះមានស្ត្រី១៣០នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅ តាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយក្រសួងសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការ Child Fund, IOM បានចុះបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (ខេត្តក្រចេះ និងខេត្តស្វាយរៀង) ។ | ០២ | ១៤០ | ៦០ |
| ២ | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង សហការជាមួយអង្គការសម្ព័ន្ធ មន្ទីរសង្គមកិច្ច នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ។ | ០១ | ៧០ | ៣១ |
| ៣ | **ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ** សហការអង្គការទេសនៈពិភពលោក បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់បទល្មើស និងការបញ្ជូនកុមាររងគ្រោះ ដល់គ្រូបង្គោលក្នុងសហគមន៍ នៅស្រុកត្បែងមានជ័យ ។ | ០២ | ៦០ | ៣៩ |
| **សរុប** | | **០៥វគ្គ** | **២៧០នាក់** | **១៣០នាក់** |

**១.២-កិច្ចប្រជុំ**ការងារដឹកនាំសម្របសម្រួលៈដោយ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានរៀបចំប្រជុំចំនួន១១លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំប្រជុំចំនួន១១លើក សរុបការងារស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេសមាន២២លើក មានអ្នកចូលរួមសរុប១,៥៧៦នាក់ មានស្រី៤៩៣នាក់។ (**ឧបសម្ព័ន្ធទី២**)

### ២. ក្រៅប្រទេស

**២.១. វគ្គបណ្តុះបណ្តាល ៖**

លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង បានសហការជាមួយ**អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ** បានបញ្ជូនមន្ត្រីជាន់ខ្ពស់ថ្នាក់ប្រធាននាយកដ្ឋាន០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងបទល្មើសដែលមានអង្គការចាត់តាំង នៅទីក្រុងហូជីមិញ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

**២.២-សិក្ខាសាលា**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ៖**
  - ចាត់បញ្ជូនលោកឧត្តមសេនីយ៍ត្រី **សុខ ស្មើ** ប្រធានក្រុមជំនួយកិច្ចសហប្រតិបត្តិការអន្តរជាតិ ចូលរួម៖
    - សិក្ខាសាលាអាស៊ានសម្រាប់អ្នកប្រតិបត្តិផ្ទាល់ ស្តីពីការចាត់វិធានការដោះស្រាយឧបសគ្គ ដល់សមភាពយេនឌ័រ នៅក្នុងការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចំពោះអំពើជួញដូរមនុស្ស និងការលើកស្ទួយដោះស្រាយតបតាមយេនឌ័រនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ (នៅទីក្រុងបាងកកប្រទេសថៃ)។
    - សិក្ខាសាលាថ្នាក់តំបន់អាស៊ាន ស្តីពីការធ្វើឲ្យមានប្រសិទ្ធភាព លើការស៊ើបអង្កេត និងការដាក់ទោសចំពោះអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម (នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន) ។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយកើតឡើង ។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថមពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស ។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬ អង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ ។

## គ.សំណូមពរ

- ➢ គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន ។
- ➢ វគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន ។
- ➢ ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច ។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការ សហប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើ អសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះខន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានាដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែមានប្រសិទ្ធភាពនិងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាជាមិនខាន ។

## V. **ទិសដៅឆមាសទី២ ឆ្នាំ២០១៧**

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ និងដកហូតសរីរាង្គជួញដូរ និងរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស ការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត ។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌ ។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួងស្ថាប័នអង្គការដៃគូក្នុងស្រុកនិងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ ។

១១. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ) ។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់តំណាក់កាលដ៏ចាំបាច់៖**

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងតំណាក់កាលនៃការជំរុញដោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់ ។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល ។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជា**អនុព័ន្ធការងារ** ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម ។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ ដែលនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនបានចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរ ដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពពលករជាដើម ។ ~~ស~~ttha

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែមិថុនា ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 853 លើក | 103,086 នាក់ | 56,168 នាក់ |
| 2 | កំពត | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នៅទូទាំងក្រុង/ស្រុក ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមាន សុវត្ថិភាព។ | លេខាធិការដ្ឋានខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងមន្ទីរពាក់ព័ន្ធ | 9 លើក | 827 នាក់ | 343 នាក់ |
| | | ផ្សព្វផ្សាយ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងយល់ពីកលល្បិចជនខិលខូចក្នុងការបោកប្រាស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន និងសាលារៀន ។ | | 4 លើក | 245 នាក់ | 128 នាក់ |
| 3 | សៀមរាប | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងវិស័យទេសចរណ៍ ដល់ លោកគ្រូ អ្នកគ្រូ និសិត្ស បញ្ញវ័ន្ត នៅវិទ្យាស្ថាន ពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរៀប ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 70 នាក់ | 33 នាក់ |
| 4 | តាកែវ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក និងស្នងការដ្ឋាននគរបាលខេត្ត | 22 លើក | 1,180 នាក់ | 477 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | | 63 លើក | 6,699 នាក់ | 3,024 នាក់ |
| 5 | ពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ និងស្រុកបាកាន ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក | 6 លើក | 232 នាក់ | 105 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅក្រុងពោធិ៍សាត់ ស្រុកបាកាន ស្រុកក្រគរ ស្រុកកណ្តៀង និងស្រុកភ្នំក្រវាញ ។ | | 127 លើក | 14,417 នាក់ | 8,371 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | បាត់ដំបង | ផ្សព្វផ្សាយ ដល់កងកម្លាំង ប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅតាមមូលដ្ឋានក្រុង/ស្រុកទូទាំងខេត្ត) ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ភូមិ-ឃុំមានសុវត្ថិភាព ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក មន្ទីរកិច្ចការនារីខេត្ត អង្គការពាក់ព័ន្ធ | 355 លើក | 36,714 នាក់ | 20,733 នាក់ |
| | | វេទិកាសាធារណៈផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំង ប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅតាមមូលដ្ឋានក្រុង/ស្រុកទូទាំងខេត្ត)។ | | 67 លើក | 3,656 នាក់ | 1,907 នាក់ |
| 7 | ឧត្តរមានជ័យ | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស នៅទូទាំងក្រុង/ស្រុក ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ យន្តការទេសន្តរប្រវេសន៍ ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន ខេត្ត/ក្រុង/ស្រុក | 31 លើក | 1,424 នាក់ | 652 នាក់ |
| 8 | ស្វាយរៀង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ។ | លេខាធិការដ្ឋាន ខេត្ត/ក្រុង/ស្រុក | 335 លើក | 14,208 នាក់ | 8,021 នាក់ |
| 9 | ព្រះសីហនុ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អង្គការពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ស្តីពីភូមិ-ឃុំមានសុវត្ថិភាព ការងារបទល្មើសគ្រប់ប្រភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស។ | លេខាធិការដ្ឋាន ខេត្ត/ក្រុង/ស្រុក និងមន្ទីរកិច្ចការនារី | 3 លើក | 164 នាក់ | 65 នាក់ |
| | | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវច្បាប់ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។ | | 1 លើក | 214 នាក់ | 149 នាក់ |
| 10 | កំពង់ធំ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ ការរំលោភបំពានផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ក្រុមការងារ គ.ខ.ប.ជ ខេត្ត/ស្រុក | 1 លើក | 164 នាក់ | 84 នាក់ |
| 11 | ក្រចេះ | ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ ការធ្វើចំណាក ស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុកមន្ទីរកិច្ចការនារីខេត្ត | 4 លើក | 189 នាក់ | 140 នាក់ |

សកម្មភាពសរុបចំនួន: 1,882 លើក

មនុស្សសរុបចំនួន: 183,489 នាក់

ស្រីសរុបចំនួន : 100,400 នាក់

Ritha

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន២២លើក) មនុស្សចំនួន១,៥៧៦នាក់ (ស្រី៤៩៣នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | - ដឹកនាំប្រជុំពិភាក្សាផ្ទៃក្នុង រៀបចំរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន **២០**នាក់ (ស្រី **០៤**នាក់) ។<br>- អញ្ជើញជាអធិបតី និងជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួល សេវាសមស្រប នៅខេត្តក្រចេះ មានសិក្ខាកាមចូលរួមចំនួន **៦៥**នាក់ (ស្រី **២៥**នាក់) ។<br>- នអញ្ជើញជាគណៈអធិបតី ក្នុងសិក្ខាសាលាស្តីពីការលើកកម្ពស់ប្រសិទ្ធិភាពនៃការចូលរួមរបស់មន្ត្រីអប់រំជាស្ត្រី ដើម្បីជានាគុណភាពវិស័យអប់រំ នៅខេត្តព្រះវិហារ មានសមាសភាពចូលរួមចំនួន **១៨០**នាក់ ។<br>- អញ្ជើញជាអធិបតី និងជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប នៅខេត្តស្វាយរៀង មានសិក្ខាកាមចូលរួមចំនួន **៦៩**នាក់ (ស្រី **៣០**នាក់) ។<br>- អញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយអង្គការ IOM ស្តីពីគម្រោងឆ្នាំ២០១៧ របស់ IOM ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដែលបានដំណើរការចប់ជាស្ថាពរមួយដំណាក់កាល និងកំពុងបន្តដំណើរការមួយដំណាក់កាលទៀត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។<br>- ដឹកនាំប្រជុំផ្ទៃក្នុង កែសម្រួលរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន **២៥**នាក់ (ស្រី **០៣**នាក់) ។<br>- អញ្ជើញជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតអាមេរិក អំពីការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ នៅសាលប្រជុំគ.ជ.ប.ជ។<br>- ដឹកនាំប្រជុំផ្ទៃក្នុង កែសម្រួលរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆមាសទី១ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន **២១**នាក់ (ស្រី **០២**នាក់) ។<br>- អញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយតំណាងអង្គការ IJM, ADHOC, WI និង LSWC ស្តីពីការស្វែងរកវិធានការបន្ទាន់ ដើម្បីជួយដល់ពលករកម្ពុជា |

Fitha

| | |
|---|---|
| | ដែលនឹងត្រូវបញ្ជូនត្រឡប់យ៉ាងច្រើន បន្ទាប់ពីអាជ្ញាធរថៃប្រកាសឲ្យប្រើព្រះរាជក្រឹត្យថ្មី ស្តីពីការគ្រប់គ្រងពលករបរទេសទាំង៨ចំណុច នៅសាលប្រជុំ គ.ជ.ប.ជ សមាសភាពចូលរួមចំនួន **១៦**នាក់ (ស្រី ០៤នាក់) ។<br>- អញ្ជើញចូលរួមសន្និសីទសិក្ខាកាមដែលធ្លាប់ទទួលការបណ្តុះ បណ្តាលនៅសាលាការិយាល័យសហព័ន្ធស៊ើបអង្កេតFBI ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក លើកទី២០ នៅ ខេត្តសៀមរាប ។<br>- ចូលរួមពិនិត្យមើល និងផ្តល់យោបល់លើសេចក្តីព្រាងឯកសារមួយចំនួន ដើម្បីរៀបចំឯក សារត្រៀមសម្រាប់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលនឹងប្រព្រឹត្តទៅនៅទីក្រុង ម៉ានីល ប្រទេសហ្វីលីពីន ។ |
| **ខេត្តបាត់ដំបង** | - ចូលរួមផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សិទ្ធិមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រៀបចំដោយអង្គការប្រតិបត្តិកុមារកម្ពុជា អ្នកចូលរួម**២៧**នាក់ (ស្រី**២០**នាក់) ។ |
| **ខេត្តឧត្តរមានជ័យ** | - ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពីតួនាទី និងភារកិច្ចដល់មន្ត្រីពាក់ព័ន្ធក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការអនុវត្តផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងយន្តការចំណាកស្រុកដោយសុវត្ថិភាព ដឹកនាំដោយលោកជំទាវ អភិបាលរងខេត្ត ទទួលបន្ទុកការងារជួញដូរមនុស្ស អ្នកចូលរួមចំនួន**៣១៥**នាក់ (ស្រី**៧៧**នាក់)។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់ការជួញដូរមនុស្ស សរុបអ្នកចូលរួមចំនួន**៤៤**នាក់ (ស្រី**៣៨**នាក់) ។ |
| **ខេត្តពោធិ៍សាត់** | - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំប្រារព្ធពិធីខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧ ដែលមានកុមារចូលរួមចំនួន**១១១**នាក់នៅសាលមន្ទីរសង្គមកិច្ចខេត្ត |
| **ខេត្តសៀមរាប** | - លោកស្រីប្រធានលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីបទបង្ហាញបណ្តាញសុវត្ថិភាពកុមារគំរូថ្នាក់ភូមិ ដែលរៀបចំដោយអង្គការស៊ីការស្នា។<br>- លោកស្រីប្រធានលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានជួបពិភាក្សាជាមួយអង្គការ IJM លើការរៀបចំសិក្ខាសាលា ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ដល់សមាជិកលេខាធិការដ្ឋានគ.ខ.ប.ជ និងអ្នកពាក់ព័ន្ធ ។<br>- មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត/ស្រុក មានអ្នកចូលរួមចំនួន**១៥០**នាក់(ស្រី**៤៧**នាក់) ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែ ឧសភា ឆ្នាំ២០១៧ ដែលមានសមាជិកចូលរួមចំនួន**៣០**នាក់ (ស្រី**១៧**នាក់)។ |
| **ខេត្តបន្ទាយមានជ័យ** | - ស្នងការដ្ឋាននគរបាលខេត្ត ចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន**០៣**រូប ប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសពលករដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញាពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- ក្រុមការងារលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំ ប្រចាំខែមិថុនា ឆ្នាំ២០១៧ ក្រោមអធិបតីភាពលោកជំទាវ ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ។ |

| | |
|---|---|
| **ស្វាយរៀង** | - មន្ត្រីការិយាល័យជំនាញនៃស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមពិធីប្រារព្ធខួបលើកទី៦៨ ទិវាកុមារអន្តរជាតិ និងខួបលើកទី១៦ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៧ ដែលមានអ្នកចូលរួមចំនួន**៥០០**នាក់(ស្រី**២២៦**នាក់) នៅសាលប្រជុំធ្នេរទន្លេខេត្ត ឧបត្ថម្ភគាំទ្រដោយអង្គការសន្តិសេនា ឆាលហ្វាន និងមីក្រូហិរញ្ញវត្ថុ ABA ។ |